**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ ៧៦ អនក្រ.បក**

# អនុក្រឹត្យ

## ស្តីពី

## ការបង្កើតតំបន់ព្រៃការពារសំរាប់អភិរក្សធនធានសេនេទិច រុក្ខជាតិ និង សត្វព្រៃ " ព្រះវិហារ "

≈≈≈≈≈

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

-បានឃើញក្រឹត្យ - ច្បាប់លេខ ៣៥ក្រ.ច ចុះថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ១៩៨៨ ស្តីពីការគ្រប់គ្រងវិស័យព្រៃឈើ

-បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ២០០០ ស្តីពី ការរៀបចំ និង ការប្រព្រឹត្ត ទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

-បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គនាថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ២០០២

# សំ រេ ច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

បង្កើតតំបន់ព្រៃការពារសំរាប់អភិរក្សធនធានសេនេទិចរុក្ខជាតិ និង សត្វព្រៃ " **ព្រះវិហារ** " ស្ថិតក្នុងខេត្តព្រះវិហារ ដើម្បីៈ

-ការពារនិងអភិរក្សរុក្ខជាតិ និង សត្វព្រៃគ្រប់ប្រភេទ ជាពិសេសប្រភេទដែលកំពុងទទួលរងគ្រោះ និងជិតផុតពូជ

-រក្សាលំនឹងមជ្ឈដ្ឋានធម្មជាតិ ដែលជាទីជំរកសំរាប់ការស្នាក់អាស្រ័យ និង ការបន្តពូជរបស់ប្រភេទសត្វព្រៃ

-សិក្សាស្រាវជ្រាវវិទ្យាសាស្ត្រ បច្ចេកទេស ដើម្បីអភិវឌ្ឍន៍និងអភិរក្សធនធានសេនេទិចរុក្ខជាតិ និងសត្វព្រៃ

-ការពារ និង ថែរក្សាប្រភពទឹក

-ជំរុញការអប់រំ ផ្សព្វផ្សាយ និង អភិវឌ្ឍន៍សហគមន៍

-បំរើសេវាកម្មវិស័យទេសចរធម្មជាតិ ។

## ជំពូកទី២

## វិសាលភាព

**មាត្រា ២.-**

ចាត់ទុកថា ធនធានសេនេទិច គឺជាការប្រមូលផ្តុំនូវរូបធាតុតំណពូជនៃបណ្តាឯកតៈឬប្រភេទរុក្ខជាតិ និងសត្វព្រៃដែលស្ថិតនៅក្នុងមជ្ឈដ្ឋានធម្មជាតិអាទិភាពមួយ តម្រូវឱ្យមានការអភិរក្សក្នុងតំបន់ជាចាំបាច់។

**មាត្រា ៣.-**

តំបន់ព្រៃការពារសំរាប់អភិរក្សធនធានសេនេទិចរុក្ខជាតិ និង សត្វព្រៃ "**ព្រះវិហារ** "មានផ្ទៃក្រឡា ទំហំ ១៩០.០២៧ហិកតា ដូចមានផែនទីភ្ជាប់ជាឧបសម្ព័ន្ធ ជាព្រំព័ន្ធខ្សែព្រំបិទ កំណត់ដោយបណ្តាចំណុចគោលដែលមាននិយាមកាៈ A(499912, 1566180) , B(492324, 1573505) , C(485465, 1592638) , D(584589, 1557069) , E(572384, 1548694) , F(576118, 1536860) , G(562677, 1534721) , H(544670, 1537216) , I(540110, 1537537) ។

## ជំពូកទី៣

## ភារកិច្ច

**មាត្រា ៤.-**

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ត្រូវធ្វើការរៀបចំ និង គ្រប់គ្រងដែនព្រៃការពារសំរាប់អភិរក្ស

ឃ

ធនធានសេនេទិចរុក្ខជាតិ និង សត្វព្រៃ " **ព្រះវិហារ** " ដោយធានានូវការអភិវឌ្ឍន៍ធនធានធម្មជាតិប្រកបដោយនិរន្តរភាព និង សំរាប់ជីវភាពរស់នៅរបស់ប្រជាជនក្នុងតំបន់នោះ ។

**មាត្រា ៥.-**

ដំណើរការនៃការរៀបចំ និង គ្រប់គ្រងតំបន់ព្រៃការពារសំរាប់អភិរក្សធនធានសេនេទិចរុក្ខជាតិ និង សត្វព្រៃ " **ព្រះវិហារ** " ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ។

## ជំពូកទី៤

## អវសានប្បញ្ញត្តិ

**មាត្រា ៦.-**

រាល់បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៧.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដីនគរូបនីយកម្ម និង សំណង់ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នដែលពាក់ព័ន្ធ អភិបាលខេត្តព្រះវិហារ ត្រូវអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ៣០ ខែកក្កដា, ឆ្នាំ២០០២

**ហ៊ុន សែន**

**កន្លែងទទួល:**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-គ្រប់ក្រសួង ស្ថាប័ន
-គ្រប់សាលាខេត្ត ក្រុង
-ដូចមាត្រា ៧
-ឯកសារ-កាលប្បវត្តិ